ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៧៤៥/២៦-០៨-២០១១

សាលដីកា

លេខ:០៩ក្រVI(ធ)/២៨-៣-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នារសៀលថ្ងៃទី២៨-៣-២០១៤ ដែលមានសមាសភាពដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សា</u>

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] -ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៧៤៥ ចុះថ្ងៃទី២៦-០៨-២០១១៖

-ជនជាប់ចោទឈ្មោះ [redacted] ស៊ិ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី២៨.០២.២០១១ ។ (ប្តឹងឧទ្ធរណ៍)

មេធាវីការពារលោក [redacted] ចន្ថា

ត្រូវចោទពីបទ:រំលោភសេពសន្ថវៈ ប្រព្រឹត្តទៅនៅភូមិត្រពាំងពពេល ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង កាលពីអំឡុងខែមករា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] ជាទីតិជន ទោសពីមុនគ្មាន (រ)ម្តាយឈ្មោះ [redacted] (ស)។ ✓



Scanned with CamScanner

ឯរឿងហេតុមានដូចតទៅ:

កាលពីអំឡុងខែមករា ឆ្នាំ២០១០ វេលាម៉ោងប្រមាណ៥និង៣០នាទីល្ងាច នៅកម្ពោតព្រៃក្នុងភូមិត្រពាំងពពេល ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង មានករណីរំលោភសេពសន្ថវៈមួយបានកើតឡើង បង្កដោយជនជាប់ចោទឈ្មោះ [redacted] ស៊ុ បានទៅចាប់រំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ចន្ថា ភេទស្រី នៅពេលនារីរូបនេះកំពុងដើររកកង្កែបម្នាក់ឯង ។ ហើយក្រោយពេលកើតហេតុនារី [redacted] ចន្ថា ពុំបានប្រាប់អ្នកណានោះទេ រហូតដល់មានកូន ។ ហើយរហូតដល់ថ្ងៃទី២០.៦.២០១០ នារី [redacted] សុផល ជាម្ដាយឃើញពោះកូនធំក៏សួរទៅកូន ទើបបានដឹងថាឈ្មោះ [redacted] ចន្ថា ត្រូវជាកូនរបស់ខ្លួននោះបានប្រាប់ថា ឈ្មោះ ស៊ុ ជាអ្នកប្រព្រឹត្តអំពើរំលោភសេពសន្ថវៈមកលើខ្លួន ហើយពេលដឹងហេតុការណ៍ហើយក៏នាំកូនទៅពិនិត្យផ្ទៃពោះ ក៏ឃើញថាមានកូនពិតមែន រួចក៏បានប្ដឹងសមត្ថកិច្ចរហូតបញ្ជូនសំណុំរឿងនេះមកតុលាការចាត់ការតាមនីតិវិធីច្បាប់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:១១(ឌ) ចុះថ្ងៃទី១៨.០៥.២០១១ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម:

១-ផ្ដន្ទាទោសឈ្មោះ [redacted] ស៊ុ ដែលមានសារភាពជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ចំនួន៥ឆ្នាំ(ប្រាំឆ្នាំ) គិតពីថ្ងៃដែលឃុំខ្លួន(ថ្ងៃទី២៨.០២.២០១១) ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងពពេល ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង កាលពីអំឡុងខែ០១ ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យឈ្មោះ [redacted] ស៊ុ សងសំណងជម្ងឺចិត្តទៅឈ្មោះ [redacted] សុផល ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣.០០០.០០០រៀល(បីលានរៀល) ។ ការទាមទារលើសពីនេះត្រូវលើកចោល ។

៣-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ជនរងគ្រោះ និង ដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី២១-១០-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញសេចក្ដីសន្និដ្ឋានរឿង ចុះថ្ងៃទី២៥-១១-២០១១ របស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ស៊ុ ឆ្លើយថា: ខ្លួនប្ដឹងឧទ្ធរណ៍ព្រោះការផ្ដន្ទាទោសខ្លួនច្រើនពេក ហើយសំណងក៏ច្រើនដែរព្រោះខ្លួនមិនបានប្រព្រឹត្តទេ ។ ផ្ទះខ្លួននៅជិតផ្ទះជនរងគ្រោះប្រហែល១០០ម ស្គាល់គ្នាតាំងពីតូច ។ ខ្លួននៅរៀនសាលា០២ខែទៅ០៣ទើបមកផ្ទះម្ដង ពេលចូលឆ្នាំឬបុណ្យភ្ជុំបិណ្ឌ ។ សតិរបស់ជនរងគ្រោះធម្មតាទេ ។ ខ្លួនពិតជាមិនបានចាប់រំលោភទេ ។ ខ្លួនសំណូមពរសុំឱ្យលើកលែងចោទប្រកាន់ទោស។

-តំណាងមហាអយ្យការសន្និដ្ឋានថា: ចម្លើយរបស់ជនរងគ្រោះ ជាចម្លើយស្ថិតក្នុងស្ថានភាពគួរឱ្យជឿទុកចិត្ត ជនរងគ្រោះជានារីភេទធ្លាប់ទាក់ទងស្គាល់គ្នារហូតមានផ្ទៃពោះ ។ ពុំមានអ្នកណាផ្សេងក្រៅពី.../



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] ស៊ី ទេជាអ្នកប្រព្រឹត្ត ទោះបីមិនបានធ្វើកោសល្យវិច័យក៏ដោយ ក៏មានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ស៊ី ដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាសាលាដំបូងខេត្ត ហេតុនេះសុំឱ្យតំកល់សាលក្រមសាលាដំបូងខេត្ត ដដែល ។

-មេធាវី [redacted] ចន្ថា ការពារជនជាប់ចោទឈ្មោះ [redacted] ស៊ី សន្និដ្ឋានថា ក្រោយពីបានស្តាប់ការសាកសួរ ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ តាមការពិនិត្យរឿងក្តី កូនក្តីខ្លួនបានឆ្លើយបដិសេធនូវគ្រប់ដំណាក់កាលតាំងពីសមត្ថកិច្ចសាលាដំបូង និងនៅសាលាឧទ្ធរណ៍នាពេលនេះ គឺកូនក្តីខ្លួនបានបដិសេធរហូត ចំពោះដើមបណ្តឹងមិនដែលចូលខ្លួនមកឆ្លើយតទល់ជាមួយកូនក្តីខ្លួនទេ ទោះបីជាបានកោះហៅចំនួន០៦លើក ក៏ជនរងគ្រោះមិនដែលចូលមកឆ្លើយដែរ គឺប្តឹងចោលតែម្តង ។ ជនរងគ្រោះប្តឹងថាកូនក្តីខ្លួនចាប់រំលោភ តើមានសាក្សីណាបានឃើញឬទេ មានទម្ងន់ពី០៥ទៅ០៦ខែទើបសង្ស័យ មកប្តឹងថាកូនក្តីខ្លួនរំលោភ គឺមានតែជនរងគ្រោះម្នាក់ប៉ុណ្ណោះដែលចោទថាកូនក្តីខ្លួនចាប់រំលោភ ។ គ្មានការធ្វើកោសល្យវិច័យ អ្វីមកបញ្ជាក់ទេ។ កូនក្តីខ្លួនបានទទួលទោសចំនួន២ភាគ៣ហើយ ហេតុនេះសូមក្រុមប្រឹក្សាមេត្តាសំរាលទោស ឬ លើកលែងទោសកូនក្តីខ្លួន ដើម្បីកូនក្តីខ្លួនបានទៅបង្រៀនសិស្សវិញ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១-០៥-២០១១ របស់ឈ្មោះ [redacted] ស៊ី ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា៣៧៥ និង ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជាម្តាយរបស់ជនរងគ្រោះឈ្មោះ [redacted] ចន្ថា បានប្តឹងចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ស៊ី ថាបានចាប់រំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ចន្ថា កាលពីអំឡុងខែមករា ឆ្នាំ២០១០ ក្នុងពេលដែលជនរងគ្រោះបានទៅផ្ទះកង្កែប ។ ក្រោយពេលចាប់រំលោភរួចមក ជនរងគ្រោះពុំបានប្រាប់អ្នកណាទេ រហូតដល់មានផ្ទៃពោះ០៥ខែ ទើបដើមបណ្តឹងមានការសង្ស័យក៏បានសួរជនរងគ្រោះ ទើបជនរងគ្រោះឆ្លើយប្រាប់ថាឈ្មោះ [redacted] ស៊ី ជាអ្នកចាប់រំលោភសេពសន្ថវៈ ។

៣-តាមចម្លើយរបស់ជនរងគ្រោះដែលឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាចម្លើយនៅតុលាការបានបញ្ជាក់ ខ្លួនស្គាល់ជនជាប់ចោទឈ្មោះ [redacted] ស៊ី ច្បាស់គឺផ្ទះនៅជិតគ្នា ហើយនៅថ្ងៃកើតហេតុពេលដែលខ្លួនទៅផ្ទះកង្កែប ឈ្មោះ ស៊ី បានចាប់ខ្លួនរំលោភសេពសន្ថវៈរហូតបានសំរេច ។ល។

៤-តាមចម្លើយរបស់ជនរងគ្រោះបានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស៊ី ពិតជាបានចាប់ជនរងគ្រោះរំលោភសេពសន្ថវៈប្រាកដមែន ព្រោះថាជនរងគ្រោះបានស្គាល់ជនជាប់ចោទយ៉ាងច្បាស់ ព្រោះជាអ្នករស់នៅភូមិជាមួយគ្នា និង មានផ្ទះក្បែរគ្នា ។

៥-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស៊ី ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងពពេល ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង កាលពីអំឡុងខែមករា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣២៩ នៃក្រមព្រហ្មទណ្ឌ ។

៦-រឿងក្តីនេះសាលាដំបូងខេត្តស្វាយរៀង បានធ្វើការអង្កេត និង លើកយកភស្តុតាង មកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៧-សាលក្រមព្រហ្មទណ្ឌលេខៈ១១(ឝ) ចុះថ្ងៃទី១៨.០៥.២០១១ របស់សាលាដំបូងខេត្តស្វាយរៀង ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

**ហេតុដូច្នេះវិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១-០៥-២០១១ របស់ឈ្មោះ [redacted] ស៊ី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ១១(ឝ) ចុះថ្ងៃទី១៨.០៥.២០១១ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលនៃការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ី ក្នុងចំណុចទី១នៃសេចក្តីសម្រេចពីការដាក់ពន្ធនាគារ០៥(ប្រាំ)ឆ្នាំ មកជាដាក់ពន្ធនាគាររយៈពេល០៥(ប្រាំ)ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល០៤(បួន)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរវិញ ។ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ៚

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ៚

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍ ។

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 21 ខែ 5 ឆ្នាំ២០14
ក្រឡាបញ្ជី

[redacted]

១១៦